**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១២៤៧/១៥ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ១ កើត ខែទុតិយាសាឍ ឆ្នាំមមែ ព.ស. ២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា គ.ស ២០១៥

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក សល់ អឿន តំណាងសហគមន៍ជនជាតិដើមភាគតិច ចារាយ**

**ភូមិតាំងសេ ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិតាំងសេ ឃុំញ៉ាង ស្រុកអណ្តូងមាស

**យោង:**
- សំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិតាំងសេ របស់លោក សល់ អឿន តំណាងសហគមន៍ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៤ ។
- លិខិតលេខ ៥០៧/១៥ ឈ.អ.ខ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីសំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិតាំងសេ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិតាំងសេ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិតាំងសេ ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិតាំងសេ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

*ចម្លងជូន*
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងទេសចរណ៍

"ដើម្បីជូនជ្រាប"
- សាលាខេត្តរតនគិរី
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី

"ដើម្បីមុខការ"
- ឯកសារ- កាលប្បវត្តិ

ជា សុផារ៉ា

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com